សុន្ទរកថារបស់**លោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ**

ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ

សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៨ កុម្ភៈ ២០១៣

- **សូមគោរព លោក ភី ណុប ចៅសង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងសាងសង់ផ្ទះកុមារ និងមណ្ឌលសហគមន៍ក្នុងភូមិអណ្តូង សង្កាត់គោករកាជាមួយតំណាងរបស់សាលាសង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលការចុះហត្ថលេខានេះត្រូវបានធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ដែលជាខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅកែលម្អបរិស្ថាននៃផ្ទះកុមារក្នុងភូមិអណ្តូងតាមរយៈការសាងសង់អគារថ្មកម្ពស់ពីរជាន់មួយស្នង និងបរិក្ខារអនាម័យផងដែរ។ ផ្ទះកុមារថ្មីនេះក៏ជាទីតាំងនៃមណ្ឌលសហគមន៍ដែលអ្នកម្តាយនៅក្នុងតំបន់អាចសិក្សាពីវិធីសាស្រ្តចិញ្ចឹមបីបាច់កុមារ និងការកែលម្អជីវភាពរស់នៅរបស់ពួកគេ។ ថវិការជំនួយដែលផ្តល់ជូនសម្រាប់គម្រោងនេះមានចំនួន៧៨,៤៣០ដុល្លាអាមេរិក។ តាមរយៈការកែលម្អបរិក្ខារនេះ យើងរំពឹងថា សមត្ថភាពទទួលយកកុមាររបស់ផ្ទះកុមារនឹងត្រូវបានបង្កើន ហើយគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់កុមារជាង៦០នាក់ដែលកំពុងស្នាក់នៅរៀនសូត្រ ព្រមទាំងម្តាយរបស់ពួកគេ ក៏ដូចជាក្មេងៗជាច្រើនដែលនឹងត្រូវចូលរៀននៅផ្ទះកុមារនេះនាពេលអនាគត។

ការអប់រំ និង អភិវឌ្ឍន៍ធនធានមនុស្សជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។ ដោយហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ទៅលើវិស័យអប់រំដោយចាត់ទុកជាមុំមួយក្នុងបណ្តាមុំទាំងបួននៃយុទ្ធសាស្រ្តចតុកោណសម្រាប់អភិវឌ្ឍន៍ជាតិ។ ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលនេះក៏កំពុងខិតខំប្រឹងប្រែងបង្កើនការទទួលបានសេវាអប់រំសម្រាប់គ្រួសារក្រីក្របំផុតផងដែរ។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យអប់រំសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ចក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការផ្តល់ជំនួយទាំងផ្នែកសម្ភារៈ និងផ្នែកបច្ចេកទេស។ គម្រោងនេះត្រូវបានធ្វើឡើងដោយអនុទ្បោមតាមគោលការណ៍ជាមូលដ្ឋាននៃជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្តល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខាថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដោយដៃគូរបស់យើងគឺ សាលាសង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញដើម្បីកុមារ និងម្តាយដែលជាជនងាយរងគ្រោះកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!